**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច រៀបចំបង្កើតជាភូមិសែនរុងរឿង ស្ថិតនៅក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៩/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ផ្ទៀងផ្ទាត់រួច

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពី ការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ " ព្រះវិហារ "

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋមានទំហំសរុប ៨៩៧ ហិកតា ស្ថិតក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម :

ភូមិសែនរុងរឿង ១ មានផ្ទៃដី ៣៣១ ហិកតា

A (៥១០១៨៦, ១៥៦៣៣២៨) B (៥១០០៧២, ១៥៦៣២០៨) C (៥០៩៩២៦, ១៥៦៣០៩៤)
D (៥០៩០៩៩, ១៥៦៣៨០៨) E (៥០៩៣៤៦, ១៥៦៤០៦៦) និង F (៥០៣៧០៦, ១៥៦៦៣១៦)
G (៥០៣៦១៧, ១៥៦៥៨៩០) H (៥០៣៤៨៦, ១៥៦៥៤៧៤) I (៥០៦៨១៦, ១៥៦៤៧៤០)
J (៥០៦៨៨៦, ១៥៦៥១៥៥) K (៥០៦៩៥៩, ១៥៦៥៥៨៧)

ភូមិសែនរុងរឿង ២ មានផ្ទៃដី ១៣១ ហិកតា

A (៥១២៣៧០, ១៥៦១៣៤២) B (៥១២២០៤, ១៥៦១១៣៧) C (៥១៤១៣៧, ១៥៥៩៥៩១)
D (៥១៤៣០៣, ១៥៥៩៧៩៦) E (៥១៤៤៦៩, ១៥៦០០០១) F (៥១២៥៣៧, ១៥៦១៥៤៧)

ភូមិសែនរុងរឿង ៣ មានផ្ទៃដី ១៣៥ ហិកតា

A (៥១៦៦៦៨, ១៥៥៨៧២៩) B (៥១៦៧៧៥, ១៥៥៨៤៨៣) C (៥១៧០១៩, ១៥៥៨៥៩៧)
D (៥១៧១៥៦, ១៥៥៨៦៥២) E (៥១៧៧០៩, ១៥៥៨៥០៨) F (៥១៧៩៥៦, ១៥៥៨៤៧៣)

G (៥១៧២០៤, ១៥៥៨៥៥៥) H (៥១៩២១៨, ១៥៥៨៧០៤) I (៥១៩១៥៩, ១៥៥៨៩៦១)

J (៥១៩១១២, ១៥៥៩២២០) K (៥១៨១០០, ១៥៥៩០៧៧) L (៥១៧៨៩៨, ១៥៥៩០០៧)

M (៥១៧២២៣, ១៥៥៩១៨៥) N (៥១៧១៧៩, ១៥៥៩១៩១) O (៥១៦៨៥៤, ១៥៥៩១០០)

P (៥១៦៥៨២, ១៥៥៨៩៧២)

ភូមិសែនរុងរឿង ៤ មានផ្ទៃដី ១៣៣ ហិកតា

A (៥២២៩២៤, ១៥៥៥៤២៥) B (៥២២៩៣២, ១៥៥៥២២៧) C (៥២៥៤៧០, ១៥៥៥៥៤១)

D (៥២៥៤៤៩, ១៥៥៥៧៦៥) E (៥២៥៤០៤, ១៥៦០០៦១) F (៥២២៨៦៦, ១៥៥៥៧៤៣)

ភូមិសែនរុងរឿង ៥ មានផ្ទៃដី ១២៧ ហិកតា

A (៥១៦៩៨២, ១៥៦៨៣០៦) B (៥១៦៨៧១, ១៥៦៨៥០៤) C (៥១៦៧៥១, ១៥៦៨៧៦១)

D (៥១៨៨៤៥, ១៥៧០០៦៩) E (៥១៨៩៦៣, ១៥៦៩៨៤២) F (៥១៩០៧២, ១៥៦៩៥៩៧)

**មាត្រា ២ :**

ត្រូវបានដកចេញផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារ សំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ "ព្រះវិហារ" ។

**មាត្រា ៣ :**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ប្រាំបីរយហាសិបប្រាំពីរហិកតា (៨៥៧ ហិកតា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ៤ :**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋទំហំ ប្រាំបីរយហាសិបប្រាំពីរហិកតា (៨៥៧ ហិកតា) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកជាសម្បទានដីសង្គមកិច្ចជូនគ្រួសារយោធិន និងនគរបាល រៀបចំបង្កើតជាភូមិសែនរុងរឿង១ ភូមិសែនរុងរឿង២ ភូមិសែនរុងរឿង៣ ភូមិសែនរុងរឿង៤ ភូមិសែនរុងរឿង៥ ស្ថិតក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និង តម្រូវការជាក់ស្តែង ។

**មាត្រា ៥ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម

វុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ




សញ្ញាសំគាល់ :

- ● ចំនុចគោល
- ▭ ព្រំប្រទល់ភូមិ
- — ផ្លូវថ្មី

COORDINATE SYSTEM
Projection: UTM
Zone: 48
Horizontal Datum: Indian 1960
Spheroid: Everest
UTM Grid: 1 Km

មាត្រដ្ឋាន ១ : ១០០ ០០០

1 0 1 2 3Km

| និយាមកាសែនសុខពៀង១ | | | | | |
|---|---|---|---|---|---|
| A | 510186 | 1563328 | F | 503706 | 1566316 |
| B | 510072 | 1563208 | G | 503617 | 1565890 |
| C | 509926 | 1563054 | H | 503486 | 1565474 |
| D | 509099 | 1563806 | I | 506816 | 1564740 |
| E | 509346 | 1564066 | J | 506886 | 1565155 |
| | | | K | 506959 | 1565587 |

| និយាមកាសែនសុខពៀង២ | | |
|---|---|---|
| A | 512370 | 1561342 |
| B | 512204 | 1561137 |
| C | 514137 | 1559591 |
| D | 514303 | 1559796 |
| E | 514469 | 1560001 |
| F | 512537 | 1561547 |

| និយាមកាសែនសុខពៀង៣ | | | | | |
|---|---|---|---|---|---|
| A | 516668 | 1558729 | I | 519159 | 1558961 |
| B | 516775 | 1558483 | J | 519112 | 1559220 |
| C | 517019 | 1558597 | K | 518100 | 1559077 |
| D | 517196 | 1558652 | L | 517898 | 1559007 |
| E | 517709 | 1558508 | M | 517223 | 1559189 |
| F | 517856 | 1558473 | N | 517179 | 1559191 |
| G | 518204 | 1558559 | O | 516854 | 1559100 |
| H | 518218 | 1558704 | P | 516582 | 1558972 |

| និយាមកាសែនសុខពៀង៤ | | |
|---|---|---|
| A | 522924 | 1559425 |
| B | 522932 | 1559227 |
| C | 525470 | 1559541 |
| D | 525449 | 1559765 |
| E | 525404 | 1560061 |
| F | 522866 | 1559743 |

| និយាមកាសែនសុខពៀង៥ | | |
|---|---|---|
| A | 516982 | 1568306 |
| B | 516871 | 1568504 |
| C | 516751 | 1568761 |
| D | 518845 | 1570069 |
| E | 518963 | 1569842 |
| F | 519072 | 1569597 |